ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សភាជំនុំព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៣០

ចុះថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៩៨ តាងនាមប្រជារាស្ត្រខ្មែរ

សាលដីកា

តុលាការកំពូល

លេខ ០៤

ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៩

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៩

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ ៖

១_ឯកឧត្តម ឌិត មុន្ទី ប្រធាន

២_ លោក ឈឹម ស៊ីផល ចៅក្រម

៣_ លោក សោម សិរីវុឌ្ឍ ចៅក្រម

៤_ លោក ប្រាក់ គឹមសាន ចៅក្រម

៥_ លោក យស់ សុខឿន ចៅក្រមរាយការណ៍

ក្រឡាបញ្ជី

លោក សាន សុផាត

តំណាងមហាអយ្យការ លោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៤៧ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៣០ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៨របស់តុលាការកំពូល ។

ពីបទ: ចោរកម្មប្រព្រឹត្តនៅភូមិរការ ឃុំផ្គរទឹកព្រ ស្រុកពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៤ បទល្មើសដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៣ច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០_៩_១៩៩២ ។

_ជនជាប់ចោទឈ្មោះញ៉ាំ ចាន់សុធា "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអន្លង់វិល ឃុំស្វាយ ស្រុកក្រាការ ខេត្តពោធិ៍សាត់ របររកស៊ីក្រុមចម្រៀង មាន

ទីលំនៅសព្វថ្ងៃភូមិលាងម៉ាស៊ីន ឃុំស្វាយលួង ស្រុកកន្សៀង ខេត្តពោធិសាត់ ឪពុកឈ្មោះញ៉ ម៉ិញញ៉ា "ស" ម្តាយឈ្មោះអាំង ផឹងអៀង "វ" ប្រពន្ធឈ្មោះគូ សៀកខេង មានកូន ១នាក់ ។ក្រៅឃុំ ។

មេធាវី គ្មាន

_ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះញ៉ាំ សេងហ៊ាង "ជាម្ចាស់បណ្តឹងសាធារណៈ" ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិសៀមរាប ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប មុខរបររកស៊ីគ្រូបង្រៀន មានទីលំនៅសព្វថ្ងៃភូមិខ្សាំ ឃុំផ្ទះរែប ស្រុកសំពៅមាស ខេត្តពោធិសាត់ ឪពុកឈ្មោះញ៉ាំ គឹម ម្តាយឈ្មោះឈាង សុន ប្រពន្ធឈ្មោះម៉េង សុខុម មានកូន ៣នាក់ ។

មេធាវី គ្មាន

_តាមបណ្តឹងសាធារណៈលេខ១៣ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់ឈ្មោះញ៉ាំ សេងហ៊ាង និងបណ្តឹងសាធារណៈលេខ១៨ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨របស់ឈ្មោះញ៉ ចាន់សុធា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៥៧ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

_តាមពាក្យបណ្តឹងចុះថ្ងៃទី ២៥-៥-៩៤ របស់ឈ្មោះញ៉ាំ សេងហ៊ាង ប្តឹងពីឈ្មោះ-ញ៉ ចាន់សុធា ដោយរៀបរាប់ថា : ឈ្មោះនេះបានឡើងទៅលើផ្ទះរបស់ខ្លួនកាលពីថ្ងៃទី២៥-៥-៩៤ វេលាម៉ោង៦ និង ៣០នាទី ពេលនោះពុំជួបខ្លួនទេ តែឈ្មោះនេះបានខ្ចីម៉ាំកង់ខ្លួនទៅការខ្លួន នៅថ្ងៃទី ២៦-៥-៩៤ ចុះតែឈ្មោះនេះបានមកផ្ទះខ្លួននៅថ្ងៃទី ២៥-៥-៩៥ទៅវិញ ។ ពេលមកនោះគាត់បានជួបនឹងឈ្មោះសុន ចន្ថា តែសុន ចន្ថាមិនអោយឈ្មោះនេះខ្ចីឡើយ ដោយនិយាយថា : ម្ចាស់គេពុំនៅទេ ឈ្មោះញ៉ ចាន់សុធា និយាយថា គាត់បាននិយាយនឹងម្ចាស់រួចហើយ ហើយឈ្មោះនេះបានរើយកទៅលើទាំងម៉ាំកង់របស់ខ្លួនមានតំលៃ១០០០ដុល្លា និង លុយបាត៥៥០០បាត ដោយបត់ក្នុងកន្សែងពោះគោ ដាក់ពីលើនិងមានសង្កត់សៀវភៅពីលើទៀតផង ។

នៅថ្ងៃទី២៥-៥-៩៤ ពេលខ្លួនត្រឡប់មកផ្ទះវិញ ស្រាប់តែបាត់ម៉ាំកង់និង លុយទាំងអស់ ពេលនោះខ្លួនទៅសួរឪពុកនិងឈ្មោះសុន ចន្ថា ហើយប្រាប់ថា ឈ្មោះ នាយ យកម៉ាំកង់បាត់ហើយ តែឈ្មោះនេះប្រកែកមិនព្រមសងខ្លួនឡើយ ។

_តាមចម្លើយជនជាប់ចោទឈ្មោះញ៉ ចាន់សុធា ឆ្លើយថា : នៅថ្ងៃទី២៥-៥-៩៤ខ្លួនបានខ្ចីម៉ាំកង់របស់ឈ្មោះញ៉ាំ សេងហ៊ាងទៅការខ្លួន ដោយសន្យាអោយខ្លួនខ្ចីនៅល្ងាចថ្ងៃទី២៦-៥-៩៤ លុះព្រឹកឡើងថ្ងៃទី២៥-៥-៩៤ខ្លួនបានទៅយកម៉ាំកង់នោះ ដោយមានមិត្តភក្តិញ៉ាំ សេងហ៊ាង នៅទីនោះជាអ្នកជួយរើ ហើយខ្លួនពុំមានឃើញអ្វីទេ ។

_បាន ឃើញដីកា លើកលែងចោទប្រកាន់លេខ២៦៤ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៤ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តពោធិសាត់ ដែលបានសំរេច : លើកលែងចោទប្រកាន់លើ ឈ្មោះញ៉ ចាន់សុធា ពីបទចោរកម្ម ប្រព្រឹត្តនៅភូមិខ្សាំ ឃុំផ្ទះរែប ស្រុកទីរួមខេត្ត ខេត្តពោធិសាត់ កាលពីថ្ងៃទី២៦-៥-៩៤ ។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៥១ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩៥ របស់ឈ្មោះ ញ៉ិវ សេងហាង ដែលប្តឹងតវ៉ាពីដីកាលើកលែងចោទប្រកាន់លេខ២២៥ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តពោធិ៍សាត់ទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍នាពេលសវនាការថា: ក្នុងរឿងនេះគ្មានភស្តុតាងបញ្ជាក់ច្បាស់ថា ឈ្មោះញ៉ា ចាន់សុធា ពិតជាយកប្រាក់ញ៉ិវ-សេងហាងឡើយ ណាមួយនៅពេលញ៉ា ចាន់សុធា ទៅយកម៉ាហ្គ្រា និងគ្រឿងអលង្ការនោះក៏មានការអនុញ្ញាតពីម្ចាស់គេដែរ ហើយមានឈ្មោះទីម៉ា ជាមិត្តភក្តិរបស់ញ៉ិវ សេងហាង ទៅជួយយកឥវ៉ាន់នោះដែរ ដោយហេតុថាក្នុងផ្ទះមានវត្តមានឪពុកក្មេកនិងកូនទាំងពីររបស់គេទៀតផង ។ ណាមួយផ្ទះនេះ មនុស្សអាចចេញចូលដោយស្រួលនិងគ្មានមន្ទិលត្រឹមត្រូវ ដូច្នេះមិនអាចចោទថាញ៉ា ចាន់សុធា យកលុយនេះបានឡើយ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៤៧ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០១-១២-៩៥ របស់ញ៉ិវ សេងហាង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាលើកលែងចោទប្រកាន់លេខ២២៥ ចស ចុះថ្ងៃទី១៩-១០-៩៥ របស់ចៅក្រមស៊ើបអង្កេតតុលាការខេត្តពោធិ៍សាត់ទុកជាបានការទាំងមូល ។

៣-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្ដឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់ឈ្មោះ ញ៉ិវ សេងហាង និងបណ្ដឹងសាទុក្ខលេខ១៨ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨របស់ឈ្មោះញ៉ា ចាន់សុធា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៤៧ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសារណាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨របស់ឈ្មោះញ៉ា ចាន់សុធា ជាម្ចាស់បណ្ដឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨របស់ឈ្មោះញ៉ិវ សេងហាង ជាម្ចាស់បណ្ដឹងសាទុក្ខ ធ្វើឡើងហួសកំណត់ច្បាប់ ។

-បានស្តាប់អំណានសារណាជានិររបស់ជនជាប់ចោទឈ្មោះញ៉ា ចាន់សុធា ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ ។

-បានស្តាប់អំណានសារណាជានិររបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះញ៉ិវ សេងហាង ជាម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះ ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា៖

១-បណ្តឹងសាទុក្ខរបស់ឈ្មោះប៉ាវ សេងហាំង និង ប៉ា ចាន់សុធា ស្ថិតក្នុងកំណត់ច្បាប់ គួរលើកយកមកពិនិត្យពិចារណា ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៤៧ ចុះថ្ងៃទី១៨-៣-៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

-បានស្តាប់អំណានសារណារបស់ឈ្មោះប៉ា ចាន់សុធា ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ។

-បានស្តាប់អំណានសារណារបស់ឈ្មោះប៉ាវ សេងហាំង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អម តុលាការកំពូលថា៖ សូមអោយក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ចុះ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីនិងរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់ឈ្មោះប៉ាវ សេងហាំង និង បណ្តឹងសាទុក្ខលេខ១៨ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨ របស់ឈ្មោះ-ប៉ា ចាន់សុធា ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើកយកមកជំនុំជំរះបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ពុំមានភស្តុតាងបញ្ជាក់ថា ឈ្មោះប៉ា ចាន់សុធា បានយកប្រាក់ ដូចដែលឈ្មោះប៉ាវ សេងហាំង បានលើកឡើងនោះឡើយ ។

-យល់ឃើញថា ការលើកឡើងរបស់ឈ្មោះប៉ាវ សេងហាំង ក្នុងសារណាចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ សុទ្ធតែជារឿងនៃអង្គហេតុដែលតុលាការថ្នាក់ក្រោមបានពិចារណារួចហើយ ។

-យល់ឃើញថា ការលើកឡើងរបស់ជនជាប់ចោទក្នុងសារណាចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៨ សំណូមពរសុំទាមទារសោហ៊ុយខាតពេលវេលា នោះជារឿងនៃអង្គហេតុ ដែលតុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាឡើយ ។

-យល់ឃើញថា ជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសារណាជូន

មកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទនិង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ។

_យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៤៧ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

ប៉ុន្តែចាត់ទុកជាចំពោះមុខ :

១_ទទួលបណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨របស់ឈ្មោះ_ច្ចាំវ សេងហាំង និង បណ្តឹងសាទុក្ខលេខ១៨ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៨របស់ឈ្មោះច្ចាំចាន់សុធា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៤៧ ចុះថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣_សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ។